# ការដាក់ទោសទណ្ឌ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍

កាលពីថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣នេះ កម្ពុជាបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំវេទិកាទីបលើកទី៤ ក្រោមប្រធានបទ "ការទប់ស្កាត់អំពើប្រល័យពូជសាសន៍" ដោយមានការជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសំណាក់រដ្ឋាភិបាលប្រទេសស៊ុីស សហការជាមួយរដ្ឋាភិបាល ប្រទេសតង់ហ្សានី និងប្រទេសអាហ្សង់ទីន ។ នាឱកាសកិច្ចប្រជុំថ្នាក់ទីបនេះ មានកិច្ចការសំខាន់មួយដែលត្រូវពិចារណាឲ្យបានដិតដល់គឺថា ដើម្បីដាក់ទោសទណ្ឌ និងទប់ស្កាត់អំពើ ប្រល័យពូជសាសន៍នាថ្ងៃអនាគតតម្រូវឲ្យមានការចូលរួមពីស្ថាប័ន និងរដ្ឋាភិបាលលើសពីមួយ ។ អំពើប្រល័យពូជសាសន៍ និងអំពើយង់ឃ្នងទាំងឡាយបានកើតឡើងចាប់តាំងពីការកកើតមនុស្សជាតិមកម្ល៉េះ ប៉ុន្តែទើបតែរយៈពេល ៧០ ឆ្នាំចុងក្រោយនេះតែប៉ុណ្ណោះ ដែលយើងចាប់ផ្តើមពង្រឹងក្របខណ្ឌគតិយុត្តិដើម្បីដោះស្រាយជំងឺដែលកំពុងតែញាំញីមនុស្សជាតិដ៏សំខាន់មួយនេះ ។

កិច្ចប្រជុំវេទិកាទីបលើកទី៤នេះគឺជាកិច្ចខិតខំប្រឹងប្រែងមួយ ដើម្បីដោះស្រាយបញ្ហាទាំងអស់ខាងលើដោយនៅក្នុងវេទិកានេះ មានការចូលរួម និងពិភាក្សាពីអ្នកតំណាងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញជាច្រើនរូបមកពីទូទាំងប្រទេសក្នុងសកលលោកដើម្បី ចែករំលែកព័ត៌មានទាំងឡាយ និងដើម្បីលើកកម្ពស់គំនិតច្នៃប្រឌិតថ្នាក់សកល ដែលចាំបាច់ក្នុងន័យទប់ស្កាត់មិនឲ្យអំពើឃោរឃៅនានាកើតឡើង ជាថ្មីទៀត ។ ក្របខណ្ឌគតិយុត្តិ ទាមទារឲ្យមានធនធានផ្សេងៗជាច្រើន ដោយសារតុលាការតែឯកឯងមិនអាចវិនិច្ឆ័យត្រឹមតែមានឆន្ទៈ របស់ខ្លួនតែប៉ុណ្ណោះបានទេ ។ ប្រទេសនីមួយៗត្រូវរួបរួមគ្នាទប់ស្កាត់ និងដាក់ទោសទណ្ឌចំពោះអំពើប្រល័យពូជសាសន៍មិនត្រឹមតែតាមរយៈផ្លូវច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតាមរយៈផ្លូវសីលធម៌ ក្នុងការធានាឲ្យប្រាកដថាពាក្យ "Never Again" ឬជាភាសាខ្មែរ "មិនកើតឡើងសាជាថ្មីម្តងទៀត" ឆ្លើយតបទៅនឹងអត្ថន័យរបស់ពាក្យនោះ ។ ខ្ញុំសូមអំពាវនាវដល់សាធារណជន បណ្តាញសារព័ត៌មាន និងរដ្ឋាភិបាលទាំងឡាយ ចាប់យកភារកិច្ចជាប្រវត្តិសាស្ត្រនៅចំពោះមុខយើងនេះដើម្បីធានាឲ្យប្រាកដថា ពាក្យ "មិនកើតឡើងសាជាថ្មីម្តងទៀត" ដក់ជាប់ក្នុងស្មារតីរបស់មនុស្សគ្រប់គ្នាជានិច្ច ។ នៅប្រទេសកម្ពុជា សំណើនេះទាមទារឲ្យមានការប្តេជ្ញាចិត្តយ៉ាងមុតមាំដើម្បីបញ្ចប់សំណុំរឿងក្តីដែលមិនទាន់ដោះស្រាយរួចរាល់នៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ការប្តេជ្ញា ចិត្តនោះគឺជាការភ្ជាប់ជាមួយនូវក្តីបារម្ភអំពីឯករាជភាពរបស់តុលាការកាតទោសមេដឹកនាំខ្មែរក្រហមនេះដែរ ។

តុលាការណាមួយក៏ដោយ ក៏ត្រូវទទួលរងនូវការរិះគន់ពី សាធារណជនដែរ ។ ការរិះគន់ដែលមានមូលដ្ឋានច្បាស់លាស់ សបញ្ជាក់អំពីលទ្ធិប្រជាធិបតេយ្យទូលំទូលាយ ។ ប៉ុន្តែ រដ្ឋាភិបាលទាំងឡាយ

មានកាតព្វកិច្ចគាំទ្រឯករាជ្យភាពរបស់តុលាការដែលមិនមែនជាការគាំទ្រទាំងងងឹតស្អុបនោះទេ ប៉ុន្តែជាការគាំទ្រក្នុងន័យស្ថាបនា ។ រដ្ឋាភិបាលទាំងឡាយមិនគួរព្រងើយកន្តើយនឹង កិច្ចការរបស់តុលាការឡើយ ប៉ុន្តែគួរតែចូលរួមប្រកបដោយការស្ថាបនាដើម្បីធានាថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានផ្តល់ឱកាសមួយដើម្បីសម្រេចការងារស្វែងរកយុត្តិធម៌របស់ខ្លួន ។ ធនធានដែលមានស្រាប់គួរតែឆ្លើយតបទៅនឹងការចង់ឃើញនូវ ការបញ្ចប់អាណត្តិរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ យើង មិនគួរអនុញ្ញាតឲ្យបញ្ហានយោបាយមកបង្អាក់ភាពប្តេជ្ញាចិត្តរបស់យើងក្នុងការស្វែងរកយុត្តិធម៌និង ការពិតជូន ជនរងគ្រោះក្នុងប្រទេសកម្ពុជារាប់លាននាក់នោះឡើយ ។

**ឆាំង យុ**